ក្លាយ
ក្លាយ
ជាអ្នក
ល្អ



ប្រឹងនិទានអប់រំ សម្រាប់កុមារ ចាប់ពី៣ឆ្នាំឡើង

និពន្ធដោយ សេង វណ្ណដា

រូបភាពដោយ Google Gemini





9 781234 567897


នៅថ្ងៃមួយ ក្នុងម៉ោងចេញលេងនៅសាលារៀនអាយ អែស ភី អែស រ៉ូ រ៉ូ បានដើរ
កាន់ថង់នំ និងដបទឹកក្រូចយ៉ាងសប្បាយរីករាយ។
ពេលញ៉ាំអស់ រ៉ូ រ៉ូ ក៏ទម្លាក់ថង់ផ្លាស្ទិក និងកំប៉ុងទទេនោះចោលនៅលើដីក្បែរ
ដើមឈើភ្លាម ដោយមិនបានយកទៅបោះក្នុងធុងសំរាមដែលនៅជិតនោះទេ។


ខណៈពេលដែល រ៉ូ រ៉ូ រៀបនឹងដើរចេញ រំពេចនោះមានសំឡេងតូចមួយ
ស្រែកឡើងៈ «អូយ! ត្រជាក់ណាស់... កុំបោះចោលខ្ញុំនៅក្រៅធុង
សំរាមអី ព្រោះខ្ញុំរងារណាស់!»
ត្រជាក់ណាស់!
ខ្ញុំរងារណាស់!


រ៉ូ រ៉ូ ភ្ញាក់ព្រើត ហើយងាកក្រោយមើលភ្លាមៗ។ គេឃើញថង់សំរាម និង
កំប៉ុងទទេនោះ មានមុខមាត់ និងភ្នែកតូចៗ កំពុងអង្គុយញ័រទទ្រើក
នៅលើដី។
គេមានឈ្មោះថា កូក កូក


រ៉ូ រ៉ូ សួរដោយភាពភ្ញាក់ផ្អើលៈ «អ្នកណាគេនិយាយហ្នឹង? ចុះហេតុអ្វីបានជាឯងរងារ?»
ជួយផង!
ជួយផង!



កូក កូក តូចនោះឆ្លើយទាំងទឹកមុខក្រៀមក្រំ៖ «គឺពួកខ្ញុំហ្នឹងហើយ! ពេលរ៉ូ រ៉ូ បោះពួកខ្ញុំចោលនៅលើដីបែបនេះ ពួកខ្ញុំគ្មានផ្ទះជ្រកទេ ត្រូវត្រូវខ្យល់ ប៉ះធូលី ហើយធ្វើឲ្យបរិស្ថានសាលារៀនយើងខូចសម្រស់ទៀតផង។
ផ្ទះដ៏កក់ក្តៅរបស់ពួកខ្ញុំ គឺនៅក្នុងធុងសំរាមឯណោះតើ!»



រ៉ូ រ៉ូ ឮហើយក៏មានអារម្មណ៍អាណិត និងភ្ញាក់រលឹកៗ
គេនិយាយ៖ «សុំទោសណា! ខ្ញុំមិនបានគិតដល់ឡើយ។ ចាំខ្ញុំជួយយកឯងទៅផ្ទះកក់ក្តៅវិញ!»



រ៉ូ រ៉ូ ក៏ប្រញាប់រើសសំរាមទាំងនោះ រួចយកទៅបោះចូលក្នុងធុងសំរាមយ៉ាងត្រឹមត្រូវ។ នៅពេលធ្លាក់ចូលក្នុងធុងសំរាម កូក កូក តូចៗទាំងនោះក៏ញញឹមយ៉ាងស្រស់ស្រាយ ហើយពោលថា៖ «អរគុណច្រើន រ៉ូ រ៉ូ ! ឥឡូវពួកខ្ញុំលែងរងារទៀតហើយ!»



ចាប់ពីថ្ងៃនោះមក កុកកុក មិនត្រឹមតែឈប់បោះសំរាមពាសវាលពាសកាលប៉ុណ្ណោះទេ ថែមទាំងបានប្រាប់មិត្តភក្តិនៅសាលាទាំងអស់ឲ្យជួយគ្នារើសសំរាម បោះចូលធុង ដើម្បីឲ្យសាលារៀនស្អាត និងមានអនាម័យជានិច្ច។


សំណួរ
• តើកូនៗត្រូវបោះចោលសំរាម នៅឯណា?
• តើកូនគួរបោះចោមសំរាម នៅក្រៅផ្ទះ ដែរឬទេ?
• តើបោះចោមសំរាម នៅក្រៅផ្ទះ ប៉ះពាល់អ្វីខ្លះ?




Brought to you by
ISPS-International School of preah sihanouk

KID Love Read is a program of
ISPS-International School of preah sihanouk that supports early reading skills and habits to develop our next generation of critical thinkers and creative innovators.

To read more books like this and get further information,
visit: isps.edu.kh

Original Story
កូកកូកស្លាវ (Brrr… Kok Kok is cold!).
Author: SENG Vanda.
Published by SPS-International School of preah sihanouk
© ISPS-International School of preah sihanouk.

This work is a modified version of the original story.
@ ISPS-International School of preah sihanouk, 2026.
Some rights reserved.



9 781234 567897